雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.135

# ប្រទេសចិន-ខេត្តយូនណាន

ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7503 ថ្ងៃសុក្រ ទី08 ខែធ្នូ ឆ្នាំ 2017

## អំពាវនាវឱ្យគណបក្សប្រទេសផ្សេងៗរួមគ្នាប្រគំតន្ត្រី "រួមជោគវាសនា"

កាលពីថ្ងៃទី ៣០ ខែវិច្ឆិកា ដល់ថ្ងៃទី ៣ ខែធ្នូ កិច្ចប្រជុំសន្ទនាថ្នាក់ដឹកនាំជាន់ខ្ពស់រវាងគណបក្សកុម្មុយនិស្តចិន និងគណបក្សផ្សេងៗលើពិភពលោកបានត្រូវរៀបចំឡើងនៅរដ្ឋធានីប៉េកាំងនៃប្រទេសចិន ។ កិច្ចប្រជុំនេះជាកិច្ចប្រជុំសន្ទនាថ្នាក់ដឹកនាំគណបក្សជាន់ខ្ពស់ទី១ដែលរៀបចំដោយគណបក្សកុម្មុយនិស្ត ចិនហើយបានទទួលនូវការចាប់អារម្មណ៍ពីសហគមន៍អន្តរជាតិ ។ កិច្ចប្រជុំនេះបានបើកទំព័រថ្មីនៃការអភិវឌ្ឍន៍របស់គណបក្សកុម្មុយនិស្តចិនហើយមានសារសំខាន់ដែលមិនអាច ជំនួសបានក្នុងប្រវត្តិសាស្ត្រអភិវឌ្ឍន៍ របស់គណបក្សផ្សេងៗលើពិភពលោក។

កិច្ចប្រជុំនេះ រៀបចំក្រោមប្រធានបទ"បង្កើតសហគមន៍រួមវាសនាមនុស្សជាតិរួមគ្នាកសាងពិភពលោកកាន់តែល្អប្រសើរ:ភារកិច្ចរបស់គណបក្ស" ដោយបានទាក់ទាញអ្នកដឹកនាំគណបក្សនិងអង្គការនយោបាយចំនួនជាង ២០០ នៃប្រទេសជាង១២០លើពិភពលោក ។ យើងទាំងអស់គ្នាសង្ឃឹមថា កិច្ចប្រជុំនេះអាចជំរុញការបង្កើតសហគមន៍រួមវាសនាមនុស្សជាតិ និងរួមគ្នាកសាងពិភពលោកកាន់តែល្អប្រសើរ ។

ប្រធានបទនៃកិច្ចប្រជុំនេះ បានបង្ហាញពីស្មារតីទំនួលខុសត្រូវរបស់គណបក្សកុម្មុយនិស្តចិន និងលក្ខណៈពិសេសរបស់ប្រទេសចិន ហើយបានឆ្លើយតបទៅនឹងបញ្ហាផ្សេងៗ ដែលទទួលបានការយកចិត្តទុកដាក់ពីពិភពលោកទាំងមូល ។ មិនតែប៉ុណ្ណោះ វានឹងអាចជួយដោះស្រាយបញ្ហាគួរឱ្យឆ្ងល់ដ៏ចម្បងរបស់មហាជន និងបានចង្អុលទិសដៅនៃការអភិវឌ្ឍន៍សម្រាប់

ការស្ថាបនា "ខ្សែក្រវាត់មួយ និងផ្លូវមួយ" បង្កប់នូវសុបិនដ៏អស្ចារ្យរបស់ប្រជាជនចិន ហើយបានជំរុញការតភ្ជាប់រវាងប្រទេសចិននិងពិភពលោក និងរួមគ្នាធ្វើការអភិវឌ្ឍ ។ ប្រទេសចិនប្រកាន់ខ្ជាប់នូវមាគ៌ាអភិវឌ្ឍន៍ដោយសន្តិភាព ខិតខំជំរុញការបង្កើតទំនាក់ទំនងអន្តរជាតិបែបថ្មី និងពួតដៃជាមួយបណ្ដាប្រទេសនានាដើម្បីដើរឆ្ពោះទៅមុខឥតឈប់ឈរ ។ ដូចប្រសាសន៍សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីកម្ពុជាថា កិច្ចប្រជុំគណបក្សពិភពលោក ដែលរៀបចំដោយគណបក្សកុម្មុយនីស្តនេះមានសារសំខាន់ជាប្រវត្តិសាស្ត្រ ។

តាមរយៈការរៀបចំកិច្ចប្រជុំនេះ គណបក្សនៃបណ្ដាប្រទេសនានា រួមគ្នាពិគ្រោះពិភាក្សា និងផ្លាស់ប្ដូរទស្សនៈដោយសមភាព ដែលនឹងអាច ជួយដោះស្រាយបញ្ហាប្រឈមរួមរបស់មនុស្សជាតិ ព្រមទាំងជំរុញឱ្យប្រទេស ផ្សេងៗដើរដល់មតិឯកភាពគ្នាអំពី យុទ្ធសាស្ត្រសំខាន់ ដែលមានពាក់ព័ន្ធ ទៅនឹងជោគវាសនា និងអនាគតរបស់ មនុស្សជាតិ ។

យុគសម័យថ្មីជំរុញឱ្យប្រទេសចិនធ្វើដំណើរតាមផ្លូវអភិវឌ្ឍន៍ថ្មី ។ វាមិនគ្រាន់តែជាផ្លូវអភិវឌ្ឍន៍ថ្មីរបស់ប្រជាជនចិនជាង១.៣០០លាននាក់ប៉ុណ្ណោះទេ ហើយក៏ជាផ្លូវអភិវឌ្ឍន៍ថ្មីរបស់ប្រជាជននៃបណ្ដាប្រទេសនានាលើពិភពលោកផងដែរ ។ ការបង្កើតសហគមន៍រួមវាសនាមនុស្សជាតិ និងរួមគ្នាកសាងពិភពលោកកាន់តែល្អប្រសើរ មិនត្រឹមតែត្រូវមានការខិតខំប្រឹងប្រែងរបស់គណបក្សកុម្មុយនីស្តចិននោះទេ ហើយក៏ត្រូវមានការចូលរួមពីគណបក្សនៃបណ្ដាប្រទេសនានា ដែលមានស្ថានភាពខុសគ្នា មានវប្បធម៌ ប្រពៃណីខុសគ្នា និងមានមនសិការខុសគ្នា ៕

**ដោយ យ៉ាន លាំង (ស៊ីនហួ ចិន)**

## វេទិកាវិនិយោគចិន-កម្ពុជាប្រារព្ធនៅក្រុងគុនមីង

នៅថ្ងៃទី២៥ ខែវិច្ឆិកា វេទិកាវិនិយោគចិន-កម្ពុជា ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គ បានរៀបចំនៅក្រុងគុនមីងនៃខេត្តយូនណាន ។

វេទិកានេះជាសកម្មភាពសំខាន់មួយ ដែលរៀបចំក្នុងឱកាសពិព័រណ៍ផលិតផលប្រទេសអនុតំបន់ទន្លេឡានឆាង-មេគង្គឆ្នាំ២០១៧ ដើម្បីជំរុញការផ្លាស់ប្ដូរ និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលសហគ្រាសស្ថាប័នហិរញ្ញវត្ថុ សមាគមឧស្សាហកម្ម និងពាណិជ្ជកម្ម និងឃ្លាំងគំនិតនៃប្រទេសទាំងពីរ ព្រមទាំងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងការ អនុវត្តគម្រោងជាក់ស្ដែង អភិវឌ្ឍន៍ឧស្សាហកម្ម និងបង្កើនការវិនិយោគ ជាដើម ។

មន្ត្រីរាជការ និងតំណាងសហគ្រាសចិន និងកម្ពុជាជាង១០០នាក់ បានចូលរួមក្នុងវេទិកានេះ ។ តំណាងខេត្តយូនណានបានឧទ្ទេសនាមអំពីស្ថានភាពជាក់ស្ដែង និងសមិទ្ធផលអភិវឌ្ឍន៍នៃការអនុវត្តគោលនយោបាយ "ដើរចេញទៅក្រៅ" របស់ខេត្តយូនណាន ចំណែកភ្ញៀវកម្ពុជាបានចូលរួមចែករំលែកអំពីបរិស្ថានវិនិយោគគោលនយោបាយទាក់ទាញអ្នកវិនិយោគ និងគម្រោងវិនិយោគរបស់ប្រទេសកម្ពុជា ។ អង្គវេទិកាបានឯកភាពគ្នាថានឹងក្ដាប់ជាប់នូវឱកាសនៃការស្ថាបនា "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ការធ្វើកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គ និងការកសាងខេត្តយូនណានឱ្យទៅជាមជ្ឈមណ្ឌលនាំផ្លូវអភិវឌ្ឍន៍សម្រាប់តំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ខិតខំបំពេញបន្ថែមគ្នាលើវិស័យហិរញ្ញប្បទាន បច្ចេកទេស ដីធ្លី និងធនធានមនុស្ស ដើម្បីជំរុញការតភ្ជាប់គ្នានៃប្រទេសទាំងពីរ និងរួមវិភាគទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងកម្រិតតំបន់ និងលើពិភពលោក ។

ស្ថាប័ន សហគ្រាសនិងអង្គការចិននិងកម្ពុជាមួយចំនួនរួមមានសមាគមជំរុញការអភិវឌ្ឍឧស្សាហកម្មអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ខេត្តយូនណាន និង CCI វិនិយោគកម្ពុជា-ចិន ជាដើម បានចុះកិច្ចព្រមព្រៀងក្នុងវេទិកានេះដើម្បីបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម ស្ថាបត្យកម្ម ទេសចរណ៍ និងផលិតកម្មជាដើម ៕ **ដោយ ជូ ហៃ**

## ពិព័រណ៍ផលិតផលប្រទេសទន្លេឡានឆាង-មេគង្គ និងវេទិកាបឹងទានឈីនៃកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គរៀបចំនៅក្រុងគុនមីង



*កម្មវិធីសម្ដែងសិល្បៈនៅ ពិព័រណ៍ផលិតផលប្រទេសទន្លេ ឡានឆាង-មេគង្គ*
*(រូបថត ដោយ Chen Fei )*

កាលពីថ្ងៃទី ២៤ ខែវិច្ឆិកា ពិព័រណ៍ផលិតផលប្រទេសអនុតំបន់ទន្លេឡានឆាង-មេគង្គឆ្នាំ ២០១៧ និងវេទិកាបឹងទានឈីនៃកិច្ចសហប្រតិបត្តិការ ទន្លេឡានឆាង-មេគង្គ បានត្រូវរៀបចំឡើងនៅក្នុងទីក្រុងគុនមីង នៃខេត្តយូនណាន ។

មន្ត្រីរាជការ សហគ្រិន អ្នកជំនាញការ និងអ្នកសារព័ត៌មានជាង ៧០០ រូប ដែលមកពីប្រទេសទន្លេឡានឆាង-មេគង្គចំនួន ៦ រួមមានប្រទេសចិន ឡាវ ថៃ វៀតណាម កម្ពុជា និងមីយ៉ាន់ម៉ា បានចូលរួមក្នុងវេទិកាបឹងទានឈី នៃកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គនេះ ។ វេទិកានេះរៀបចំក្រោមប្រធានបទ"រួមគ្នាពិគ្រោះពិភាក្សាអំពីវិធានការថ្មី និងបង្កើតយន្តការថ្មី ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ដោយឈ្នះ-ឈ្នះ" ។ តំណាងដែលមកពីប្រទេសផ្សេងៗបានបញ្ចេញយោបល់ថា វេទិកានេះនឹងជំរុញឱ្យកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គឈានចូលក្នុងយុគសម័យថ្មី និងបង្កើតជានិម្មាបនកម្មអភិវឌ្ឍន៍ថ្មីក្នុងតំបន់ទន្លេឡាឆាង-មេគង្គ ។

ក្នុងឱកាសពិព័រណ៍ផលិតផលប្រទេសអនុតំបន់ទន្លេឡានឆាង-មេគង្គឆ្នាំ២០១៧ សហគ្រាសដែលមកពីប្រទេស ចិន ឡាវ ថៃ វៀតណាម កម្ពុជា មីយ៉ាន់ម៉ា កូរ៉េខាងត្បូង ម៉ាឡេស៊ី ប៉ាគីស្ថាន និងអ៊ីរ៉ង់ជាដើម បាននាំមក និងដាក់តាំងពិព័រណ៍នូវអនុផលកសិកម្ម ផលិតផលទេសចរណ៍វប្បធម៌ គ្រឿងតុបតែងផ្ទះ គ្រឿងសង្ហារិម វត្ថុសិប្បកម្ម ផលិតផលសម្រាប់ថែរក្សាសុខភាព និងផលិតផលវប្បធម៌ពិសេស ។ល។

គួរបញ្ជាក់ថា ខេត្តយូនណានមានទីតាំងភូមិសាស្ត្រដ៏មានឧត្ដមភាព ដោយស្ថិតនៅទីប្រសព្វគ្នានៃរង្វង់សេដ្ឋកិច្ចចិន រង្វង់សេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ និងរង្វង់សេដ្ឋកិច្ចអាស៊ីខាងត្បូង ។ ការរៀបចំពិព័រណ៍ផលិតផលប្រទេសទន្លេឡានឆាង-មេគង្គនេះ គឺជាសកម្មភាពអនុវត្តន៍ជាក់ស្ដែងរបស់ខេត្តយូនណាន ដើម្បីចូលរួមយ៉ាងសកម្មក្នុងការស្ថាបនា"ខ្សែក្រវាត់មួយ និងផ្លូវមួយ" និងពង្រឹងកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គ ៕ **ដោយ ឈូតុងហួ**

## ប្រទេសចិនបើកការិយាល័យកុងស៊ុលនៅខេត្តសៀមរាប


*ពិធីបើកសម្ពោធដាក់ឱ្យ ដំណើរការការិយាល័យកុងស៊ុលចិន នៅខេត្តសៀមរាប (រូបថត ដោយYu Jiangning )*

នៅថ្ងៃទី ២៦ ខែវិច្ឆិកា ស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជា រៀបចំពិធីបើកសម្ពោធដាក់ឱ្យដំណើរការការិយាល័យកុងស៊ុលនៅខេត្តសៀមរាប ។

លោក ស្យុង ពួ ឯកអគ្គរដ្ឋទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជា លោក លីវ ជីជា ប្រធានការិយាល័យកុងស៊ុលប្រទេសចិនប្រចាំនៅខេត្តសៀមរាប លោក លី ធុជ ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងលោក ឃឹម ប៊ុនសុង អភិបាលខេត្តសៀមរាបបានអញ្ជើញចូលរួមក្នុងពិធីនេះ។

លោក ស្យុង ពួ មានប្រសាសន៍ថា ការបើកការិយាល័យកុងស៊ុលនៅខេត្តសៀមរាបបានបង្ហាញពីការយកចិត្តទុកដាក់កម្រិតខ្ពស់របស់រដ្ឋាភិបាលចិនក្នុងការបង្កើនទំនាក់ទំនងរវាងប្រទេសចិននិងកម្ពុជា និងបានបង្ហាញពីសមិទ្ធផលថ្មី នៃការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការពហុវិស័យរវាងប្រទេសទាំងពីរ ។ ការិយាល័យកុងស៊ុលនេះនឹងអាចជំរុញការផ្លាស់ប្ដូរ និងកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ វប្បធម៌ និងទេសចរណ៍រវាងប្រទេសចិននិងតំបន់ពាយ័ព្យនៃប្រទេសកម្ពុជា ។

លោក ទេសរដ្ឋមន្ត្រី លី ធុជ និងលោកបណ្ឌិត ឃឹម ប៊ុនសុង បានថ្លែងថា ការិយាល័យកុងស៊ុលនៅខេត្តសៀមរាប នៃស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជានឹងអាចជួយរឹតចំណងមិត្តភាពរវាងប្រទេសកម្ពុជានិងចិន បង្កើនការផ្លាស់ប្ដូរលើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម វប្បធម៌ និងបុគ្គលិករវាងប្រទេសទាំងពីរ ព្រមទាំងទាក់ទាញឱ្យទេសចរចិនកាន់តែច្រើនទៅដើរលេងប្រទេសកម្ពុជា ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា ការិយាល័យកុងស៊ុលប្រចាំនៅខេត្តសៀមរាបគឺជាស្ថាប័នកុងស៊ុលទី១របស់ប្រទេសចិន ដែលបើកឱ្យដំណើរការនៅក្រៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។ កិច្ចការនៃការិយាល័យកុងស៊ុលប្រទេសចិនប្រចាំនៅខេត្តសៀមរាបគ្របដណ្ដប់លើខេត្តចំនួន៦ រួមមានខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តឧត្ដរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តព្រះវិហារ ៕

**ដោយ ម៉ាវ ភីងហ្វី (ស៊ីនហួចិន)**

## បឹងឈីពីមានទឹកថ្លាឆ្វង់បឹងអឺហៃបានប្រភពទឹកស្អាត

បឹងឈីពីជាប្រភពទឹកដ៏សំខាន់មួយរបស់បឹងអឺហៃ ។ ប៉ុន្មានឆ្នាំនេះ សាលារដ្ឋបាលស្រុកអឺយាន់នៃមណ្ឌលស្វយ័តជនជាតិប៉ៃ តាលី ខេត្តយូនណាន បានចាត់វិធានការដ៏មានប្រសិទ្ធភាពមួយចំនួនធំ ដើម្បីកែលម្អបរិស្ថានជុំវិញបឹងឈីពី តាមរយៈការកាត់បន្ថយការបញ្ចេញជាតិបំពុលបរិស្ថាន ការស្ដារតំបន់ដីសើម ការជីកស្រះទឹកស្អាត និងការដាំដុះរុក្ខជាតិជាដើម ។ វិធានការទាំងនេះបានធ្វើឱ្យបឹងឈីពីមានទឹកថ្លាឆ្វង់ ដែលមានគុណភាពទឹកជាប់លំដាប់លេខII ជាអចិន្ត្រៃយ៍ និងបានរក្សាសុវត្ថិភាពនៃការផ្គត់ផ្គង់ទឹកផឹកសម្រាប់ប្រជាជនតាមតំបន់ ហើយក៏បានធ្វើឱ្យបឹងអឺហៃទទួលបានប្រភពទឹកដ៏ស្អាតផងដែរ ៕


*ទូកសម្អាតស្មៅទឹកសាបនៅ បឹង ឈីពី ( រូបថត Xinhua )*